ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៤៧ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

យោងតាមមាត្រា១៧៨ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ច្បាប់នេះត្រូវមានអនុភាពអនុវត្តក្រោយពេលចូលជាធរមានរយៈពេល ១២ ខែ គឺនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដែលជាកាលបរិច្ឆេទអនុវត្តទូទៅ។ ច្បាប់នេះបានចែងកំណត់ ឱ្យរៀបចំលិខិតបទដ្ឋានគតិយុត្ត មួយចំនួនសម្រាប់អនុវត្ត។ នៅក្នុងរយៈពេល ដែលលិខិតបទដ្ឋានគតិយុត្ត មិនទាន់បានរៀបចំរួចរាល់ជាស្ថាពរ ការចេញសេចក្តីណែនាំសម្រាប់អនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនគឺជាកិច្ចការចាំបាច់ ដើម្បីតម្រង់ទិសមន្ត្រីអនុវត្តនៅគ្រប់ថ្នាក់ឱ្យបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្ត និងប្រព័ន្ធចុះបញ្ជីសមស្រប ដែលត្រូវដាក់ឱ្យអនុវត្ត។ ទន្ទឹមនឹងនេះ មាត្រា១៧៣ នៃច្បាប់នេះ ក៏បានបញ្ញត្តិអំពីអន្តរកាលនៃការបន្តអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលមានកន្លងមក រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងច្បាប់នេះ។

ក្នុងន័យនេះ ដើម្បីធានាឱ្យការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ប្រកបដោយប្រសិទ្ធភាព និងសំដៅឆ្លើយតបទៅនឹងគោលបំណងនៃច្បាប់ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចតទៅ៖

## I. បទប្បញ្ញត្តិដែលត្រូវអនុវត្ត

អនុលោមតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម បទប្បញ្ញត្តិដែលត្រូវអនុវត្ត រួមមាន មាត្រា១៨ (ទីកន្លែងចុះបញ្ជីកំណើតរស់) មាត្រា១៩ (រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់) មាត្រា២០ (អ្នករាយការណ៍អំពីកំណើតរស់) មាត្រា២៣ (ពាក្យសុំចុះបញ្ជីកំណើតរស់) មាត្រា២៥ (នីតិវិធីចុះបញ្ជីកំណើតរស់) មាត្រា៣៨ (ការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះមួយឆ្នាំ) មាត្រា៣៩ (ការចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ) មាត្រា៤២ (ទីកន្លែងចុះបញ្ជីមរណភាព) មាត្រា៤៣ (រយៈពេលចុះបញ្ជីមរណភាព) មាត្រា៤៤ (អ្នករាយការណ៍អំពីមរណភាព) មាត្រា៥២ (ពាក្យសុំចុះបញ្ជីមរណភាព) មាត្រា៥៤ (នីតិវិធីចុះបញ្ជីមរណភាព) មាត្រា៦៣ (ការអនុញ្ញាតឱ្យបូជា ឬបញ្ចុះសព) មាត្រា៦៤ (ការចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះមួយឆ្នាំ) មាត្រា៦៥ (ការចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ) មាត្រា៦៧ (ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍) មាត្រា៦៨ (ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍) មាត្រា៦៩ (ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍) និងមាត្រា១៦៤ (សេវាដែលមិនតម្រូវឱ្យបង់កម្រៃ)។ ដោយឡែកបទប្បញ្ញត្តិផ្សេងទៀត ក្រៅពីបទប្បញ្ញត្តិដែលបានកំណត់ខាងលើ ត្រូវអនុវត្តបន្ទាប់ពីមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## II. ការអនុវត្តការចារចុះបញ្ជីអត្រានុកូលដ្ឋាន

ការចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិមួយចំនួននៅក្នុងជំពូកទី២ (ការចុះបញ្ជីអត្រានុកូលដ្ឋាន) នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដូចខាងក្រោម៖

### ១. ការចុះបញ្ជីកំណើតរស់

បុគ្គលទទួលខុសត្រូវជាអ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

- ម្តាយរបស់ទារក
- ឪពុករបស់ទារក
- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្តាយទារក
- ញាតិជានីតិជនដែលមើលថែទារក
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់។

រាល់កំណើតរស់ដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលបានកើតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់។

អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នៅទីតាំងណាមួយដូចខាងក្រោម៖

- ឃុំ សង្កាត់ ដែលកំណើតរស់បានកើតឡើង ឬ
- ឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ។

**ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីកំណើតរស់ ជាឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។**

រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលទារកបានកើត។
- ករណីអ្នករាយការណ៍ មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទារកកើត អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃដែលទារកកើត ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។
- ករណីអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍អាចដាក់ពាក្យស្នើសុំចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ដោយត្រូវបញ្ជាក់បន្ថែមអំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ និងត្រូវមានការធានាអះអាងរបស់សាក្សី ១(មួយ)រូប ជានីតិជន ដែលដឹងអំពីព្រឹត្តិការណ៍កំណើតរស់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីកំណើតរស់ រួមមានឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកកើត។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មិនត្រូវបដិសេធពាក្យសុំចុះបញ្ជីកំណើតរស់ដោយសារខ្វះព័ត៌មានដែលទាក់ទងទៅនឹងឪពុក ឬម្តាយឡើយ។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ អាចចុះបញ្ជីដោយឆន្ទានុសិទ្ធិ ឬដោយទទួលការអនុញ្ញាតពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ បានទទួលព័ត៌មានអប្បបរមា តាមការជូនដំណឹងពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ និងការចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ត្រូវចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងចេញសំបុត្របញ្ជាក់កំណើត រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ត្រូវជំនួសដោយការចុះបញ្ជីកំណើតរស់ នៅក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើត និងចេញសំបុត្រកំណើតវិញ។

**២.ការចុះបញ្ជីមរណភាព**

បុគ្គលដែលទទួលខុសត្រូវជាអ្នករាយការណ៍អំពីមរណភាព ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

- ម្ដាយ ឬឪពុក ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន
- សហព័ទ្ធរបស់មរណជន
- ញាតិជានីតិជនរបស់មរណជន
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់
- បុគ្គល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធតាមការកំណត់ដោយច្បាប់ ក្នុងករណីមរណភាពដោយមូលហេតុខុសប្រក្រតី ឬគួរឱ្យសង្ស័យ ឬបណ្ដាលពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ។

រាល់មរណភាពដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលបានទទួលមរណភាពនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាព។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវចេញលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសព។ គ្មានសពណាអាចត្រូវបានបូជា ឬបញ្ចុះ ដោយគ្មានលិខិតអនុញ្ញាតឱ្យបូជា ឬបញ្ចុះសព ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចឡើយ លើកលែងមានបទប្បញ្ញត្តិផ្សេង។

អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាព នៅទីតាំងណាមួយដូចខាងក្រោម៖

- ឃុំ សង្កាត់ ដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង ឬ
- ឃុំ សង្កាត់ ដែលមរណជនស្នាក់នៅ។

**ទម្រង់ និងព័ត៌មានពាក្យសុំចុះបញ្ជីមរណភាព ជាឧបសម្ព័ន្ធទី២ នៃសេចក្ដីណែនាំនេះ។**

រយៈពេលសម្រាប់ចុះបញ្ជីមរណភាព ត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ ដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង។
- ករណីអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង អ្នករាយការណ៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

- ករណីអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះ ១(មួយ)ឆ្នាំ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល ១(មួយ)ឆ្នាំ ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ និងត្រូវមានការធានាអះអាងរបស់សាក្សី ១(មួយ)រូប ជានីតិជនដែលដឹងអំពីព្រឹត្តិការណ៍មរណភាពនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយមិនតម្រូវឱ្យមានសេចក្ដីសម្រេចពីតុលាការនោះទេ។

ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីមរណភាព រួមមានឈ្មោះ ភេទ ថ្ងៃខែឆ្នាំ និងទីកន្លែងដែលមរណជនទទួលមរណភាព។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ អាចចុះបញ្ជីដោយឆន្ទានុសិទ្ធិ ឬដោយទទួលការអនុញ្ញាតពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ បានទទួលព័ត៌មានអប្បបរមា តាមការជូនដំណឹងពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**៣. ការចុះបញ្ជីអាពាហ៍ពិពាហ៍**

បុរសម្នាក់និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ នៅទីតាំងណាមួយដូចខាងក្រោម៖

- ឃុំ សង្កាត់ ដែលបុរសនោះរស់នៅ ឬ
- ឃុំ សង្កាត់ ដែលនារីនោះរស់នៅ។

**ទម្រង់ និងព័ត៌មានពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាឧបសម្ព័ន្ធទី៣ នៃសេចក្ដីណែនាំនេះ។**

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ មានសុពលភាពរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយជាសាធារណៈ ដោយធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល ១០(ដប់)ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះ អាចប្ដឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេល ១០(ដប់)ថ្ងៃនោះ។ ប្រសិនបើគ្មានការជំទាស់នៅក្នុងរយៈពេល ១០(ដប់)ថ្ងៃនោះទេ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលា នៅក្នុងរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ក្នុងករណីទុកឱ្យហួសរយៈពេលនេះ បុរសនារី ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ឡើងវិញ។

**៤. បម្រាមនៃការចុះបញ្ជីអត្រានុកូលដ្ឋាន**

ហាមមនុស្សម្នាក់ ចុះបញ្ជីអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗលើសពី ១ដង នៅកន្លែងដដែល ឬនៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៥. តម្លៃសេវាចុះបញ្ជីអត្រានុកូលដ្ឋាន**

សេវាចុះបញ្ជីកំណើតរស់ ចុះបញ្ជីមរណភាព ចុះបញ្ជីអាពាហ៍ពិពាហ៍ និងចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ១(មួយ)ច្បាប់ មិនតម្រូវឱ្យបង់តម្លៃសេវានោះឡើយ។

**III. ការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានពាក់ព័ន្ធការងារចុះបញ្ជីអត្រានុកូលដ្ឋាន**

ចំពោះបែបបទ នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវបន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ដូចខាងក្រោម៖

- អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា៥២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
- សេចក្តីណែនាំលេខ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត
- សេចក្តីណែនាំលេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីវិធានការពង្រឹងការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន
- សេចក្តីណែនាំលេខ០០៦ សណន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤ ស្តីពីបែបបទនីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីណែនាំផ្សេងទៀតពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានស្ថាប័ន/អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំចុះបញ្ជីកំណើតរស់

| **ព័ត៌មានអ្នកកើត** | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ : ☐ ប្រុស ☐ ស្រី |
| នាមខ្លួន | | | |
| នាមត្រកូល | ជាអក្សរឡាតាំង | | សញ្ជាតិ : |
| នាមខ្លួន | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃទី ខែ ឆ្នាំ | កូនទី |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | | |

| **ព័ត៌មានឪពុកម្ដាយ** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ |
| ស្ថានភាព(រស់-ស្លាប់) | ☐ រស់ ☐ ស្លាប់ | ☐ រស់ ☐ ស្លាប់ |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | |
| មុខរបរពេលទារកកើត | | |
| ទីលំនៅពេលទារកកើត<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| ទីលំនៅឯបរទេស | | |
| លេខអត្តសញ្ញាណប័ណ្ណ | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅ<br>កម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ | | |

**ការចុះបញ្ជីកំណើតក្នុង ឬក្រោយរយៈពេលអនុគ្រោះ**

**ក្នុងករណីការចុះបញ្ជីកំណើតក្រោយរយៈពេល៣០ថ្ងៃ ឬ០១ឆ្នាំ សូមបញ្ជាក់ហេតុផល :**

| ក្នុងករណីការចុះបញ្ជីកំណើតផុតរយៈពេលអនុគ្រោះ០១ឆ្នាំ បន្ទាប់ពីកំណើតកើតឡើង សូមផ្ដល់ព័ត៌មានសាក្សីដូចខាងក្រោម: | | |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | ភេទ ☐ ប្រុស ☐ ស្រី |
| ជាអក្សរឡាតាំង | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | សញ្ជាតិ : |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| លេខអត្តសញ្ញាណប័ណ្ណ | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ | | |
| ស្នាមមេដៃស្ដាំសាក្សី | ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស. ២៥<br>ថ្ងៃទី ខែ ឆ្នាំ២០<br>ឈ្មោះ | |

| **ព័ត៌មានអ្នករាយការណ៍** |
|---|
| ត្រូវជាអ្វីជាមួយអ្នកកើត ☐ ម្ដាយ ☐ ឪពុក ☐ ផ្សេងៗ (សូមបញ្ជាក់) |
| **ប្រសិនបើអ្នករាយការណ៍មិនមែនជាម្ដាយឬឪពុក សូមបំពេញព័ត៌មានខាងក្រោម :** |

| | | |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | ភេទ ☐ ប្រុស ☐ ស្រី |
| ជាអក្សរឡាតាំង | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | សញ្ជាតិ : |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| លេខអត្តសញ្ញាណប័ណ្ណ | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ | | |
| លេខទូរស័ព្ទទំនាក់ទំនង | | |
| ស្នាមមេដៃស្ដាំអ្នករាយការណ៍ | ខ្ញុំសូមបញ្ជាក់ថារាល់ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវប្រាកដមែន។<br>ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស. ២៥<br>ថ្ងៃទី ខែ ឆ្នាំ២០ | |

| | |
|---|---|
| | ឈ្មោះ ............................ |
| ថ្ងៃ.................... ខែ............ ឆ្នាំ.................. ស័ក ព.ស. ២៥.........<br>............................................ ថ្ងៃទី...... ខែ............ ឆ្នាំ២០......<br>**មន្ត្រីទទួលពាក្យសុំ**<br><br>ហត្ថលេខា និងឈ្មោះ : ............................ | |

**ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើតរស់ ៖**

**១. ឯកសារបញ្ជាក់អំពីកំណើតរស់ (មួយក្នុងចំណោមខាងក្រោម)**

- ☐ ទម្រង់ជូនដំណឹងអំពី កំណើតរស់ចេញដោយមូលដ្ឋានសុខាភិបាល ឬ
- ☐ បណ្ណសុខភាពកុមារ ឬ
- ☐ លិខិតបញ្ជាក់អំពីកំណើតចេញដោយមេភូមិ

**២. ឯកសារបញ្ជាក់អត្តសញ្ញាណម្តាយនិងឪពុក និងអ្នករាយការណ៍(បើអ្នករាយការណ៍មិនមែនម្តាយឪពុក)**

- ☐ សម្រាប់ប្រជាពលរដ្ឋខ្មែរ
  - ☐ សំបុត្រកំណើត ឬ ☐សេចក្តីចម្លងសំបុត្រកំណើត : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
  - ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
  - ☐ លិខិតឆ្លងដែន : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ និង
  - ☐ សៀវភៅស្នាក់នៅ ☐សៀវភៅគ្រួសារ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍
- ☐ សម្រាបជនបរទេស
  - ☐ លិខិតឆ្លងដែន : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
  - ☐ អត្តសញ្ញាណប័ណ្ណចេញដោយប្រទេសសាមី : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
  - ☐ បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
  - ☐ សំបុត្រកំណើត : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ និង
  - ☐ សៀវភៅស្នាក់នៅ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍

**៣.ឯកសារបញ្ជាក់ពីបិតុភាព**

- ☐ សំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយ ឬ ☐ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយ ឬ
- ☐ ករណីគ្មានឯកសារណាមួយបញ្ជាក់ពីបិតុភាព អ្នករាយការណ៍ត្រូវតែជាឪពុកនិងម្តាយ

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំរៀបអាពាហ៍ពិពាហ៍

| **ព័ត៌មានបុរស នារី** | | **បុរស** | **នារី** |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| នាមត្រកូល | ជាអក្សរឡាតាំង | | |
| នាមខ្លួន | ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | | |
| ទីលំនៅឯបរទេស | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា<br>លេខ ថ្ងៃ ខែ ឆ្នាំ | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី | | | |
| លេខ និងថ្ងៃ ខែ ឆ្នាំ បណ្ណប្រកាស<br>អាពាហ៍ពិពាហ៍ | | | |
| **ព័ត៌មានឳពុក** | | **ខាងបុរស** | **ខាងនារី** |
| នាមត្រកូល និងនាមខ្លួន | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ |
| ស្ថានភាព (រស់-ស្លាប់) | | ☐ រស់ ☐ ស្លាប់ | ☐ រស់ ☐ ស្លាប់ |
| មុខរបរបច្ចុប្បន្ន | | | |

| | | |
|---|---|---|
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| **ព័ត៌មានម្តាយ** | **ខាងបុរស** | **ខាងនារី** |
| នាមត្រកូល និងនាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ |
| ស្ថានភាព (រស់-ស្លាប់) | ☐ រស់ ☐ ស្លាប់ | ☐ រស់ ☐ ស្លាប់ |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| លេខទូរស័ព្ទទំនាក់ទំនងរបស់អ្នកស្នើសុំ | | |
| ស្នាមមេដៃស្តាំរបស់បុរសនារីជាអ្នកស្នើសុំ | ខ្ញុំសូមបញ្ជាក់ថារាល់ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវប្រាកដមែន។<br>ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស. ២៥<br>ថ្ងៃទី ខែ ឆ្នាំ២០<br><br>ឈ្មោះ ឈ្មោះ | |

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស. ២៥

ថ្ងៃទី ខែ ឆ្នាំ២០

**មន្ត្រីទទួលពាក្យសុំ**

ហត្ថលេខា និងឈ្មោះ

**ឯកសារភ្ជាប់សម្រាប់ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ៖**

☐ **សម្រាប់ពលរដ្ឋខ្មែរ**

- ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ : របស់ ☐ បុរស ☐ នារី ឬ
- ☐ លិខិតឆ្លងដែន : របស់ ☐ បុរស ☐ នារី ឬ

- ☐ សំបុត្រកំណើត : របស់ ☐ បុរស ☐ នារី ឬ
- ☐ សេចក្តីចម្លងសំបុត្រកំណើត : របស់ ☐ បុរស ☐ នារី និង
- ☐ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ : របស់ ☐ បុរស ☐ នារី និង
- ☐ សៀវភៅស្នាក់នៅ ☐សៀវភៅគ្រួសារ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់ ☐ បុរស ☐ នារី និង/ឬ
- ☐ លិខិតទទួលយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន

☐ សម្រាប់ជនបរទេស

- ☐ លិខិតឆ្លងដែន : របស់ ☐ បុរស ☐ នារី ឬ
- ☐ អត្តសញ្ញាណប័ណ្ណចេញដោយប្រទេសសាមី : របស់ ☐ បុរស ☐ នារី ឬ
- ☐ បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត : របស់ ☐ បុរស ☐ នារី ឬ
- ☐ សំបុត្រកំណើត : របស់ ☐ បុរស ☐ នារី
- ☐ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយប្រទេសសាមី ឬស្ថានទូត : របស់ ☐ បុរស ☐ នារី ឬ
- ☐ សៀវភៅស្នាក់នៅ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់ ☐ បុរស ☐ នារី



៩០ ៤

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំចុះបញ្ជីមរណភាព

| **ព័ត៌មានមរណជន** | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ ☐ ប្រុស ☐ ស្រី |
| នាមខ្លួន | | | |
| នាមត្រកូល | ជាអក្សរឡាតាំង | | សញ្ជាតិ : |
| នាមខ្លួន | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃទី ខែ ឆ្នាំ | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | | |
| ស្ថានភាពសព<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | ☐ នៅលីវ ☐ រៀបការហើយ(បានចុះបញ្ជី)<br>☐ មេម៉ាយប្ដីស្លាប់ ☐ ពោះម៉ាយប្រពន្ធស្លាប់<br>☐ មេម៉ាយលែងលះគ្នា ☐ ពោះម៉ាយលែងលះគ្នា<br>☐ កំពុងរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្ដីប្រពន្ធ | |
| មុខរបររបស់សពមុនពេលស្លាប់ | | | |
| ទីលំនៅរបស់សពមុនពេលស្លាប់<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | | |
| ទីលំនៅឯបរទេស | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា<br>លេខ ថ្ងៃ ខែ ឆ្នាំ | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ | | ថ្ងៃទី ខែ ឆ្នាំ | |
| ទីកន្លែងស្លាប់<br>ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | | |
| មូលហេតុស្លាប់តាមបណ្ដឹងរបស់អ្នករាយការណ៍ | | | |

| **ព័ត៌មានឪពុកម្ដាយ** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ |

| | | |
|---|---|---|
| ស្ថានភាព (រស់-ស្លាប់) | ☐ រស់ ☐ ស្លាប់ | ☐ រស់ ☐ ស្លាប់ |
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ក្រុង-ស្រុក-ខណ្ឌ<br>រាជធានី-ខេត្ត ប្រទេស | | |
| មុខរបរបច្ចុប្បន្ន | | |
| លេខអត្តសញ្ញាណប័ណ្ណ | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា<br>លេខ ថ្ងៃ ខែ ឆ្នាំ | | |

**ការចុះបញ្ជីមរណភាពក្លួច ឬក្រោយរយៈពេលអនុគ្រោះ**

**ក្នុងករណីការចុះបញ្ជីមរណភាពក្រោយរយៈពេល១៥ថ្ងៃ ឬ០១ឆ្នាំ សូមបញ្ជាក់ហេតុផល :**

**ក្នុងករណីការចុះបញ្ជីមរណភាពផុតរយៈពេលអនុគ្រោះ០១ឆ្នាំ បន្ទាប់មរណភាពកើតឡើង សូមផ្តល់ព័ត៌មានសាក្សីដូចខាងក្រោម :**

| | | |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | ភេទ ☐ ប្រុស ☐ ស្រី |
| ជាអក្សរឡាតាំង | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | សញ្ជាតិ : |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | | |
| លេខអត្តសញ្ញាណប័ណ្ណ | | |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា<br>លេខ ថ្ងៃ ខែ ឆ្នាំ | | |
| ស្នាមមេដៃស្តាំសាក្សី | ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥<br>ថ្ងៃទី ខែ ឆ្នាំ២០<br><br>ឈ្មោះ | |

**ព័ត៌មានអ្នករាយការណ៍**

ត្រូវជាអ្វីនឹងសព ☐ ម្តាយ ☐ ឪពុក ☐ ប្រពន្ធ ☐ ប្តី ☐ ផ្សេងៗ(សូមបញ្ជាក់)

**ប្រសិនបើអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក សូមបំពេញព័ត៌មានខាងក្រោម :**

| | | |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | | ភេទ ☐ ប្រុស ☐ ស្រី |
| ជាអក្សរឡាតាំង | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី ខែ ឆ្នាំ | សញ្ជាតិ |
| មុខរបរបច្ចុប្បន្ន | | |

| | |
|---|---|
| ទីលំនៅបច្ចុប្បន្ន<br>ផ្ទះលេខ ឈ្មោះផ្លូវ ភូមិ ឃុំ-សង្កាត់<br>ក្រុង-ស្រុក-ខណ្ឌ រាជធានី-ខេត្ត ប្រទេស | ...<br>... |
| លេខអត្តសញ្ញាណប័ណ្ណ | ... |
| លេខលិខិតឆ្លងដែន<br>មានសុពលភាព ត្រឹមថ្ងៃ ខែ ឆ្នាំ | ...<br>... |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅ<br>កម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ | ...<br>... |
| លេខទូរស័ព្ទទំនាក់ទំនង | ... |
| ស្នាមមេដៃស្តាំអ្នករាយការណ៍ | ខ្ញុំសូមបញ្ជាក់ថារាល់ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវប្រាកដមែន។<br>ថ្ងៃ... ខែ... ឆ្នាំ... ស័ក ព.ស.២៥...<br>... ថ្ងៃទី... ខែ... ឆ្នាំ២០...<br><br>ឈ្មោះ ... |

ថ្ងៃ... ខែ... ឆ្នាំ... ស័ក ព.ស.២៥...

... ថ្ងៃទី... ខែ... ឆ្នាំ២០...

**មន្ត្រីទទួលពាក្យសុំ**

ហត្ថលេខា និងឈ្មោះ ...

**ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមរណភាព ÷**

១. **ឯកសារបញ្ជាក់អំពីមរណភាព**

- ☐ ទម្រង់ជូនដំណឹងអំពីមរណភាពចេញដោយមូលដ្ឋានសុខាភិបាល
- ☐ ឯកសារផ្សេងទៀតបញ្ជាក់ពីមរណភាព

២. **ឯកសារបញ្ជាក់អត្តសញ្ញាណមរណជន និងអ្នករាយការណ៍**

☐ សម្រាប់ប្រជាពលរដ្ឋខ្មែរ

- ☐ សំបុត្រកំណើត ឬ☐សេចក្តីចម្លងសំបុត្រកំណើត : របស់☐ មរណជន ☐ អ្នករាយការណ៍ ឬ
- ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ : របស់☐ មរណជន ☐ អ្នករាយការណ៍ ឬ
- ☐ លិខិតឆ្លងដែន : របស់☐ មរណជន ☐ អ្នករាយការណ៍ និង
- ☐ សៀវភៅស្នាក់នៅ ☐សៀវភៅគ្រួសារ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់☐ មរណជន ☐ អ្នករាយការណ៍

☐ សម្រាប់ជនបរទេស

- ☐ លិខិតឆ្លងដែន : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
- ☐ អត្តសញ្ញាណប័ណ្ណចេញដោយប្រទេសសាមី : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
- ☐ បណ្ណស្នាក់នៅអចិន្ត្រៃយ៍ជនបរទេសអន្តោប្រវេសន្ត : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ ឬ
- ☐ សំបុត្រកំណើត : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍ និង
- ☐ សៀវភៅស្នាក់នៅ ឬ☐លិខិតបញ្ជាក់ទីលំនៅ : របស់☐ឪពុក ☐ម្តាយ ☐អ្នករាយការណ៍